អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# **សេចក្តីប្រកាសព័ត៌មាន**

**ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦**

**កិច្ចប្រជុំពេញអង្គចៅក្រម អ.វ.ត.ក លើកទី២** នឹងប្រារព្ធធ្វើនៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២០ ដល់ទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៦ នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) រាជធានីភ្នំពេញ។

របៀបវារៈគឺដើម្បីពិចារណាទៅលើសេចក្តីព្រាងវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ដែលរៀបរៀងដោយគណៈកម្មាធិការទទួលបន្ទុកវិធាន និងនីតិវិធី រួមជាមួយមតិយោបល់នានាដែលបានលើកឡើងដោយចៅក្រមផ្សេងទៀត និងដោយការិយាល័យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត មេធាវីការពារក្តីនាំមុខ និងការិយាល័យរដ្ឋបាល ព្រមទាំងពីបណ្តាបុគ្គល និងអង្គការដែលមានចំណាប់អារម្មណ៍ ដែលមានរយៈពេលពីរសប្តាហ៍ក្នុងការផ្តល់មតិយោបល់ទៅលើសេចក្តីព្រាង ដែលបានផ្សព្វផ្សាយកាលពីថ្ងៃសុក្រទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦។

ក្នុងអំឡុងពេលកិច្ចប្រជុំពេញអង្គ អង្គការក្រៅរដ្ឋាភិបាលនឹងមានឱកាសក្នុងការជួបប្រាស្រ័យ និងធ្វើបទបង្ហាញនូវមតិយោបល់របស់ខ្លួន។ នៅពេលចប់កិច្ចពិភាក្សារបស់ខ្លួន ចៅក្រមទាំងអស់នឹងបោះឆ្នោតអនុម័តវិធានផ្ទៃក្នុង។

***តំណាងសារព័ត៌មាននឹងត្រូវអញ្ជើញឲ្យចូលថតរូបភាពនៅ CJCC នៅថ្ងៃច័ន្ទទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ៨:០០ ព្រឹកជាកំហិត។***

***ទីកន្លែង៖ មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-ជប៉ុន***
***មហាវិថីសហព័ន្ធរុស្ស៊ី នៅក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ***



Original EN: 01699282-01699282

*សន្និសីទសារព័ត៌មានរួមគ្នាដោយចៅក្រមជាតិ និងចៅក្រមអន្តរជាតិនឹងធ្វើឡើងនៅទីកន្លែងដដែល នៅថ្ងៃសៅរ៍ទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ៤រសៀល។*

*អាស្រ័យហេតុនេះ យើងសូមស្នើឲ្យតំណាងសារព័ត៌មានដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួម មេត្តាទាក់ទងមកមន្ត្រីអ្នកនាំពាក្យ អ.វ.ត.ក លោក រាជ សម្បត្តិ តាមរយៈលេខទូរស័ព្ទ ០១២ ៨៩១ ៥៦៧ ឬតាមរយៈអ៊ីមែល៖* **reachsambath@hotmail.com** *ត្រឹមវេលាថ្ងៃត្រង់ ថ្ងៃអាទិត្យទី១៩ ខែវិច្ឆិកា៕*